# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ សិទ្ធិបញ្ចេញយោបល់នៅប្រទេសថៃ ឆ្លុះបញ្ចាំងមកមើលសិទ្ធិបញ្ចេញយោបល់នៅកម្ពុជា ។

**Website: www.hoksavann.org**

ថ្ងៃទី១ មេសា ២០១០



ប្រទេសថៃជាប្រទេសមួយនៅជិតខាងប្រទេសកម្ពុជា ។ តាមប្រវត្តិសាស្ត្រ ប្រទេសនេះតែងតែឈ្លានពានប្រទេសកម្ពុជា រហូតខេត្តជាច្រើនរបស់ប្រទេសកម្ពុជាបានត្រូវថៃរំលោភយក ។ ពេលនេះ យើងគួរពិនិត្យមើលលក្ខណៈពិសេសនៃប្រទេសថៃ ដែលមិនដែលចំណុះប្រទេសណាឡើយ ។ បារាំងធ្វើអាណានិគមនិយមលើប្រទេសនៅឥណ្ឌូចិន វៀតណាម ខ្មែរ និងលាវ ចំណែកប្រទេសថៃគេចខ្លួនរួច សូម្បីជប៉ុនឈ្នះបារាំងក្នុងរយៈពេលខ្លី ក៏ថៃមិនចំណុះជប៉ុនឡើយ ។ ថៃក្រហមដែលមាននិន្នាការទៅលើទ្រឹស្តីម៉ៅ-សេទុងបានត្រូវរលាយ ដោយការប៉ិនប្រសប់របស់អ្នកដឹកនាំថៃ ធ្វើសន្ធិសញ្ញាសម្ងាត់ជាមួយប្រទេសចិនកុម្មុយនិស្ត ។ ជាមួយគ្នានោះ ក៏បានធ្វើសម្ព័ន្ធ-ភាពខាងយោធាជាមួយអាមេរិក ដើម្បីឲ្យសហរដ្ឋអាមេរិកការពារប្រទេសខ្លួន ។ ដូច្នេះប្រទេសថៃបានយកមហាអំណាចទាំងពីរជាមិត្ត ដើម្បីជៀសវាងសង្គ្រាមកុំឲ្យកើតមានដល់ប្រទេសខ្លួន ។ តើអ្នកដឹកនាំនយោបាយខ្មែរអនុវត្តនយោបាយក្រៅប្រ-ទេសបែបណា បានជាចេះតែកើតសង្គ្រាមនៅប្រទេសរបស់ខ្លួនជាញឹកញាប់បែបនេះ ? ។

បញ្ហាផ្ទៃក្នុង ថៃទោះបីមានវិបត្តិនយោបាយខ្លាំងក្លាយ៉ាងណាក៏ដោយ ថៃមិនឃើញពឹងបរទេសឲ្យជួយកំទេចគូបដិបក្ខរបស់ខ្លួន ដែលជាជាតិថៃដូចគ្នាឡើយ ។ ជាពិសេសក្នុងពេលនេះ ថៃកំពុងមានវិបត្តិនយោបាយ ដែលចេញពីគណបក្សភឿថៃ ដែលហៅថាពួកអាវក្រហម ដែលគាំទ្រលោកថាក់ស៊ីន ដែលត្រូវទម្លាក់ដោយរដ្ឋប្រហារឆ្នាំ២០០៦ បានធ្វើបាតុកម្មរាប់សែននាក់ បង្ខំឲ្យលោកអាភីស៊ិតជានាយករដ្ឋមន្ត្រីបច្ចុប្បន្នចុះចេញពីតំណែង ហើយឲ្យរំលាយរដ្ឋសភារួចបោះឆ្នោតជាថ្មី ។ លោកអាភីស៊ិតចេញមកពីគណបក្សប្រជាធិបតេយ្យ ដែលគេហៅថាពួកអាវលឿង កាលមិនទាន់ឡើងកាន់អំណាចបានធ្វើបាតុកម្មប្រឆាំងពួកអាវក្រហម រហូតកាន់កាប់វាលយន្តហោះសុវណ្ណភូមិ ដែលធ្វើឲ្យអ្នកដំណើរជាប់គាំងនៅទីនោះអស់ពេលជាច្រើនថ្ងៃ ។ ឥឡូវនេះ ពួកអាវក្រហមបានប្រឆាំងនឹងពួកអាវលឿងវិញម្តង ដោយចោទថាលោកអាភីស៊ិតឡើងកាន់អំណាចដោយរដ្ឋប្រហារ ត្រូវតែចុះចេញពីតំណែង ។ អ្នកនយោបាយខ្មែរមើលឃើញថា លោកអាភីស៊ិតរបស់គណបក្សប្រជាធិបតេយ្យនេះ មានគំនិតជាតិនិយមជ្រុល បណ្តាលឲ្យមានបញ្ហាជាមួយប្រទេសកម្ពុជា ដោយបានទាមទារយកដីនៅជុំវិញប្រាសាទព្រះវិហាររបស់ខ្មែរដោយផែនទីដែលគូរដោយខ្លួនឯងជាឯកតោភាគី ហើយប្រឆាំងនឹងការដាក់ប្រាសាទព្រះវិហារជាមត៌កពិភពលោក ។ រដ្ឋាភិបាលខ្មែរបានតែងតាំងលោកថាក់ស៊ីនជាអតីតនាយករដ្ឋមន្ត្រីថៃដែលគេទម្លាក់ចេញពីតំ-ណែង ឲ្យធ្វើជាទីប្រឹក្សាសេដ្ឋកិច្ចជាតិខ្មែរ ។ គេមើលឃើញថា ថៃហាក់ដូចជាយកបញ្ហាប្រាសាទព្រះវិហាររបស់ខ្មែរជាចំ-ណាប់ខ្មាំងរបស់នយោបាយខ្លួន ។ ចំពោះបញ្ហានេះ អ្នកនយោបាយខ្មែរត្រូវតែប្រុងប្រយ័ត្នកុំឲ្យច្រឡំនយោបាយថៃ ព្រោះថៃប្រភេទណាក៏ដោយ ក៏នៅតែថៃគ្នាគេ គំនិតជាតិនិយមរបស់គេខ្ពស់ណាស់ គេពុំផ្តល់ប្រយោជន៍ឲ្យខ្មែរ ធ្វើឲ្យខូចប្រយោជន៍ជាតិគេឡើយ ។ មួយទៀត បើប្រុងប្រយ័ត្នអំពីចលនាឈ្លានពានទឹកដីពីថៃ ក៏ត្រូវប្រុងប្រយ័ត្នអំពីចលនាឈ្លានពានទឹកដីពីវៀតណាមក្នុងពេលជាមួយគ្នា ព្រោះប្រទេសទាំងពីរនេះមានមហិច្ឆិតាចង់បានទឹកដីខ្មែរជាបន្តទៅទៀតមិនខុសគ្នាឡើយ។

វិបត្តិនយោបាយដែលប្រព្រឹត្តទៅនៅប្រទេសថៃ ជាកិច្ចការផ្ទៃក្នុងរបស់ប្រទេសថៃ យើងមិនវែកញែកអំពីហេតុផលនៃវិបត្តិនេះឡើយ យើងគ្រាន់តែធ្វើការសង្កេតឃើញសិទ្ធិបញ្ចេញយោបល់របស់ប្រទេសនេះ ប្រៀបមកសិទ្ធិបញ្ចេញយោ-បល់នៅប្រទេសកម្ពុជា ឲ្យស្របតាមប្រធានបទនៃអត្ថបទនេះ ។វិបត្តិនយោបាយនេះ កើតពីគណបក្សនយោបាយប្រឆាំងគ្នា គេសង្កេតឃើញគណបក្សក្រុមអាវលឿងប្រឆាំងនឹងគណបក្សក្រុមអាវក្រហមក្តី ដែលសុទ្ធតែបញ្ចេញសកម្មភាពដោយធ្វើបាតុកម្ម ប៉ុន្តែគេពុំឃើញមានវិធានការរបស់រាជរដ្ឋាភិបាលថៃដែលកាន់អំណាចបង្ក្រាបពួកបាតុករដោយអំពើហឹង្សាបែបណាមួយទៅលើគណបក្សប្រឆាំងឡើយ ។ មួយទៀត អ្នកកាន់អំណាចថៃមិនបានចោទពួកបាតុករ ជាពិសេសអ្នកដឹកនាំបាតុកម្មឲ្យតុលាការកាត់ទោសឡើយ ។ ពីមុន ពួកប្រជាធិបតេយ្យអាវលឿងបានធ្វើបាតុកម្មប្រឆាំងពួកអាវក្រហម រហូតត្រួតត្រាវាលយន្តហោះសុវណ្ណភូមិ ក៏មិនឃើញអ្នកកាន់អំណាចថៃប្រើវិធានការបង្ក្រាប ឬដាក់ប្រទេសថៃឲ្យស្ថិតនៅក្នុងភាពអាសន្នឡើយ ។ បាតុកម្មពេលនោះ ត្រូវខាតថវិកាអស់ច្រើនណាស់ ជាពិសេសប្រាក់ចំណូលដែលបានមកពីទេសចរ ។ អាជ្ញាធរថៃពេលនោះក៏មិនបានចោទពួកបាតុករណាម្នាក់ ដែលធ្វើឲ្យប្រទេសខាតបង់នេះឡើយ ។ នៅពេលនេះទៀត ពួកអាវក្រហមដែលគាំទ្រលោកថាក់ស៊ីន អតីតនាយករដ្ឋមន្ត្រីដែលត្រូវគេទម្លាក់ពីតំណែង បានធ្វើបាតុកម្មអស់ពីរសប្តាហ៍មកហើយ បង្ខំឲ្យលោកអាភីស៊ិតចុះចេញពីតំណែងនាយករដ្ឋមន្ត្រីនិងរំលាយសភា ក៏មិនឃើញរាជរដ្ឋាភិបាលអាភីស៊ិតប្រើអំពើហឹង្សាទៅលើក្រុមបាតុករ ដែលមានគ្នារាប់សែននាក់ មិនបានចោទអ្នកដឹកនាំបាតុកម្មឡើយ ។ មិនតែប៉ុណ្ណោះ គណ-បក្សភឿថៃដែលជាក្រុមប្រឆាំងអាចប្រើវិទ្យុ ទូរទស្សន៍ និងសារពត៌មានស្រែកថ្កោលទោសនាយករដ្ឋមន្ត្រីអាភីស៊ីតទៀតផង ។ ក្រុមអាវក្រហមដែលមានគ្នាពី៣០ទៅ៥០នាក់ បានមកជួបលោកថាក់ស៊ីននៅលើទឹកដីនៃប្រទេសកម្ពុជា ក៏មិនឃើញ

អ្នកកាន់អំណាចថៃបច្ចុប្បន្នចោទក្រុមនោះឡើយ ។ ប៉ូលិសរាប់ម៉ឺននាក់គ្មានកាន់អាវុធ គ្រាន់តែកាន់ខែលការពារខ្លួន ឃ្លាំមើលក្រុមបាតុករ កុំឲ្យប្រើអំពើហិង្សាប៉ុណ្ណោះ គឺជាប៉ូលិសការពារសន្តិសុខឲ្យប្រជាពលរដ្ឋធ្វើបាតុកម្មដោយសន្តិវិធីបានយ៉ាងល្អប្រពៃណាស់ ។ ឥឡូវនេះ អាភីស៊ិតនាយករដ្ឋមន្ត្រីសុខចិត្តចរចាជាមួយក្រុមបាតុករជាគណបក្សប្រឆាំង ដោយមានភាគីម្ខាងបីនាក់ ។ ទោះបីការចរចាអស់រយៈកាលជាច្រើនម៉ោងចំនួន២ដងមកហើយ នៅពេលយើងសរសេរអត្ថបទនេះ មិនទាន់បានសំរេចក្នុងការស្រុះស្រួលគ្នាក៏ដោយ ក៏ចាត់ថាភាគីទាំងពីរមានការទោរទន់រកគ្នា ដោះស្រាយបញ្ហានយោបាយនេះដោយសន្តិវិធី ។ លើកយកព្រឹត្តិការណ៍ធ្វើបាតុកម្មនៅប្រទេសថៃនេះបញ្ជាក់ថា ប្រជាពលរដ្ឋថៃមានសិទ្ធិបញ្ចេញយោបល់តាមរយៈការធ្វើបាតុកម្មដោយបរិបូណ៌ ដោយមិនមានការរាំងរានិងការប្រើអំពើហិង្សាពីរាជរដ្ឋាភិបាលថៃ ហើយមិនកំណត់ចំនួនអ្នកធ្វើបាតុកម្មដូចជាច្បាប់ធ្វើបាតុកម្មរបស់ខ្មែរ ដែលទើបបានអនុម័តនោះឡើយ ។

លើកយកបាតុកម្មរបស់ប្រទេសថៃនៅឆ្នាំ២០១០នេះ មកប្រៀបធៀបបាតុកម្មនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៩៨ មានការខុសគ្នាស្រឡះ ។ បាតុកម្មមួយបានកើតឡើងនៅឆ្នាំ១៩៩៨នោះ ជាបាតុកម្មរបស់ប្រជាពលរដ្ឋខ្មែរ ដែលចូលរួមដោយគណបក្សប្រឆាំងរាប់ម៉ឺនរាប់សែននាក់ រាជរដ្ឋាភិបាលខ្មែរមិនបានសម្របសម្រួលចរចាគ្នាឡើយ ផ្ទុយទៅវិញបានបញ្ជាប៉ូលិស កងរាជអាវុធហត្ថ បាញ់ប្រហារទៅលើក្រុមបាតុករទៅវិញ ដែលធ្វើឲ្យប្រជាពលរដ្ឋ មាននិស្សិតរហូតដល់ព្រះសង្ឃដែលព្រះអង្គរួមគ្នាទៅឃាត់ បានត្រូវស្លាប់និងសុគត និងត្រូវរបួសជាច្រើន ។ ការបង្រ្កាបដោយអំពើហិង្សានេះ ពិតមែនតែបាតុកម្មត្រូវស្ងប់ស្ងាត់ដោយការភ័យខ្លាចគ្មានហ៊ានកំរើក ប៉ុន្តែផ្លូវចិត្តរបស់ពួកគេទំនងជាពុំស្ងប់ទេ ហើយចាត់ទុកព្រឹត្តិការណ៍ឆ្នាំ១៩៩៨នេះ ជាមេរៀនប្រវត្តិសាស្ត្រ ។

តើអ្នកដឹកនាំខ្មែរពេលនេះនិងទៅអនាគតទៀត ល្មមឈប់លើកកាំភ្លើងបាញ់ប្រជាពលរដ្ឋរបស់ខ្លួនហើយឬនៅ ? ច្បាប់ក្នុងរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្នគ្មានទោសប្រហារជីវិតទេ ប៉ុន្តែអ្នកកាន់អំណាចនៅតែសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួន ដូចព្រឹត្តិការណ៍ឆ្នាំ១៩៩៨នេះជាភស្តុតាងស្រាប់ ។ ក្រៅពីនោះ មានអ្នកលួចបាញ់សម្លាប់រកមុខមិនឃើញ ។ ប្រជាពលរដ្ឋខ្លះក្រោកឡើងការពារដីរបស់ខ្លួន បានត្រូវគេបាញ់សម្លាប់ ដូចជាករណីប្រជាពលរដ្ឋនៅអូរជ្រៅខេត្តបាត់ដំបង ។ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបញ្ចេញយោបល់តាមមធ្យោបាយណាមួយមានការធ្វើបាតុកម្មជាដើម តាមច្បាប់ជាតិនិងច្បាប់អន្តរជាតិ ដោយគ្មានការគំរាមកំហែង ដែលរាជរដ្ឋាភិបាលខ្លួនឯងក៏បានចុះហត្ថលេខាយល់ព្រម ។៚